រដ្ឋាភិបាល/ទឹកជំនន់

**ការណ៍ពិត ៖** ទឹកជំនន់ ឬហានិភ័យទឹកជំនន់ នាពេលបច្ចុប្បន្ននេះ កំពុងកើតមានឡើង តាមតំបន់នានា នៃ Seattle ។ វាអាចបោកបក់ធ្វើឱ្យលោកអ្នកដួលបាន នៅពេលវាមានកម្រិតកម្ពស់ទឹក ត្រឹមតែប្រាំមួយអ៊ិញប៉ុណ្ណោះ ។

**អ្វីដែលត្រូវធ្វើ ៖**

- កុំព្យាយាម ដើរ ឬបើកបរ ឆ្លងកាត់តំបន់មានទឹកជំនន់ ។ ប្រសិនបើរថយន្តរបស់លោកអ្នករលត់ នៅក្នុងទឹកជំនន់ ត្រូវចេញពីរថយន្តឱ្យបានឆាប់ ហើយទៅរកតំបន់ខ្ពស់ ។ រថយន្តអាចត្រូវបោកបក់ទៅឆ្ងាយ ដោយទឹកជម្រៅពីរហ្វីតបាន ។
- នៅឱ្យឆ្ងាយពីទឹកកំពុងហូរ។ លោកអ្នកអាចត្រូវ ទឹកហូរជម្រៅប្រាំមួយអ៊ីញ អូសបោកឱ្យដួលបាន ។
- ប្រសិនបើទីលំនៅរបស់លោកអ្នក មានទឹកជន់ ត្រូវបិទសេវាបម្រើបម្រាស់ (utilities) ចោលទាំងអស់ រហូតដល់ពេលមន្ត្រីគ្រោះអាសន្ន ប្រាប់លោកអ្នកថា មានសុវត្ថិភាព អាចបើកវាវិញបានហើយ ។
- ប្រើទឹកស្អាតច្រកដប រហូតដល់ពេលលោកអ្នកដឹងថា ទឹករបស់លោកអ្នក មានសុវត្ថិភាព អាចទទួលទានបាន ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- ***ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮអំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។***

**តំណរបណ្តាញដែលមានប្រយោជន៍ ៖**

http://www.seattle.gov/emergency-management/what-if/hazards/floods

http://www.kingcounty.gov/healthservices/health/preparedness/disaster/FloodHouse.aspx

http://mil.wa.gov/emergency-management-division/hazards/flood